ក្រសួងរ៉ែ និងថាមពល

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីការងារ
# វិស័យធនធានរ៉ែ និងប្រេងកាត
# (ផ្នែកអាប់ស្ទ្រីម) សម្រាប់ឆ្នាំ ២០១៤-២០១៨
# (យុទ្ធសាស្ត្រធនធានរ៉ែ ២០១៨)





ឆ្នាំ ២០១៤

# មាតិកា


អារម្ភកថា ១

១. សេចក្តីផ្តើម ៣

២. ស្ថានភាពបច្ចុប្បន្ននៃវិស័យធនធានរ៉ែ និងប្រេងកាត ៤

៣. ចក្ខុវិស័យ និងរបៀបវារៈយុទ្ធសាស្ត្រសំខាន់ៗ ៦

៤. វិធានការ និងកម្មវិធីការងារ ៧

៥. អាទិភាពកម្មវិធីការងារ និងពេលវេលាអនុវត្ត ១២

៦. សន្ទស្សន៍ប្រសិទ្ធផលរំពឹងទុក សម្រាប់ត្រួតពិនិត្យ និង
វាយតម្លៃលទ្ធផលនៃការអនុវត្តន៍ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ១៤

៧. គោលការណ៍មូលដ្ឋានរបស់ក្រសួងរ៉ែ និងថាមពល
ក្នុងយុទ្ធសាស្ត្រធនធានរ៉ែ ២០១៨ ១៨

៨. កំណែទម្រង់ស្ថាប័នកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ១៩

# អារម្ភកថា

បន្ទាប់ពីក្រសួងរ៉ែ និងថាមពល ដែលទើបនឹងត្រូវបានបង្កើតឡើង និងប្រកាសជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ កន្លងទៅនេះ នេះគឺជាពេលវេលាដ៏សមស្របមួយ ដែលក្រសួងរ៉ែ និងថាមពល ត្រូវកំណត់ដាក់ចេញនូវរបៀបវារៈយុទ្ធសាស្ត្រសំខាន់ៗរបស់ខ្លួន សម្រាប់ឆ្នាំ ២០១៤-២០១៨ ។

ជាជំហានបឋមរបស់យើង ក្រសួងរ៉ែ និងថាមពល នឹងត្រូវចាប់ផ្តើមពីការដកស្រង់នូវបណ្តា មេរៀនបទពិសោធន៍កន្លងមកក្នុងវិស័យធនធានរ៉ែ និងប្រេងកាត ជំរុញបន្តកិច្ចការដែលជារបៀបវារៈចាស់ រួមជាមួយ និងរបៀបវារៈថ្មីៗថែមទៀត ដើម្បីបង្កើតនូវរបត់ថ្មីមួយយ៉ាងសំខាន់ ក្នុងការបន្តជំរុញអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានរ៉ែ និងប្រេងកាតទាំងអស់ ប្រកបដោយសុចរិតភាព ប្រសិទ្ធភាព ព្រមទាំងបង្កើតឲ្យបាននូវកំលាំងចលករថ្មីមួយយ៉ាងសំខាន់ និងការពួតផ្គុំកំលាំងគ្នា(Synergy) រវាងវិស័យ ថាមពល និងវិស័យធនធានរ៉ែ និងប្រេងកាត សម្រាប់ការជំរុញវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម។

ធនធានរ៉ែ និងប្រេងកាត គឺជាដើមទុនដ៏មានតម្លៃរបស់ជាតិ សម្រាប់ការជំរុញ និងអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គម និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ការធ្វើអាជីវកម្ម ដើម្បីទាញយកមកប្រើប្រាស់នូវបណ្តាធនធានទាំងនេះ គឺជាការវិនិយោគរបស់ជាតិ ដើម្បីទទួលបាននូវផលប្រយោជន៍ ជាវឌ្ឍនភាពរុងរឿងនៃសង្គមជាតិ និងភាពល្អប្រសើរនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់។ ទន្ទឹមនេះ ការធ្វើអាជីវកម្មធនធានទាំងនេះ ជាទូទៅ ជៀសមិនផុតពីផលប៉ះពាល់ផ្សេងៗ ចំពោះបរិស្ថាន សង្គម និងជាពិសេសចំពោះសហគមន៍មូលដ្ឋាន។ ដូច្នេះ បេសកកម្មចំបងរបស់ក្រសួងរ៉ែ និងថាមពល គឺការប្រកាន់យកនូវទស្សនវិស័យដែលជំរុញឲ្យការអភិវឌ្ឍន៍ និងអាជីវកម្មធនធានរ៉ែ និងប្រេងកាត បញ្ចៀសឲ្យបានជាអតិបរិមា

នូវផលប៉ះពាល់អវិជ្ជមានផ្សេងៗ ដល់បរិស្ថាន និងសង្គម ព្រមទាំងការពារ និងជំរុញលើកកម្ពស់ផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ដើម្បីប្រែក្លាយការវិនិយោគក្នុងវិស័យនេះ បានប្រកបដោយទិន្នផលសេដ្ឋកិច្ច-សង្គមខ្ពស់បំផុត។

ទស្សនវិស័យ និងក្របខ័ណ្ឌយុទ្ធសាស្ត្រដែលត្រូវបានកំណត់ដាក់ចេញនេះ នឹងបង្កើតជាដំណើរផ្លូវដ៏លំបាក និងស្មុគស្មាញមួយ សម្រាប់យើងទាំងអស់គ្នា។ នៅលើដំណើរផ្លូវនេះ ភាពជាដៃគូរយ៉ាងជិតស្និទ្ធ និងប្រកបដោយទំនុកចិត្ត រវាងផ្នែកសាធារណៈ បណ្តាញសង្គមស៊ីវិល និងផ្នែកឯកជន គឺជាកត្តាកំណត់ភាពជោគជ័យរបស់យើង ក្នុងបណ្តាទិសដៅយុទ្ធសាស្ត្រទាំងអស់របស់យើង ក៏ដូចជាការធានាការពារបាននូវផលប្រយោជន៍យូរអង្វែងរបស់ជាតិនៅក្នុងការអភិវឌ្ឍន៍វិស័យធនធានរ៉ែ និងប្រេងកាតនេះ។

ភ្នំពេញ. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤

ហត្ថលេខា

**ស៊ុយ សែម**

រដ្ឋមន្ត្រី

## ១. សេចក្តីផ្តើម

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ត្រូវបានចងក្រងឡើង ដើម្បីកំណត់ទិសដៅ យុទ្ធសាស្ត្ររយៈពេលខ្លី និងមធ្យម និងកម្មវិធីការងារសំខាន់ៗរបស់ក្រសួងរ៉ែ និងថាមពល សម្រាប់ឆ្នាំ ២០១៤-២០១៨។ យុទ្ធសាស្ត្រនេះគ្របដណ្តប់លើវិស័យធនធានរ៉ែ និងប្រេងកាត (ផ្នែកអាប់ស្ទ្រីម)។ ដោយឡែកផ្នែកដោនស្ទ្រីមនៃវិស័យប្រេងកាត នឹងត្រូវគ្របដណ្តប់ដោយក្របខ័ណ្ឌយុទ្ធ-សាស្ត្រដោយឡែកមួយផ្សេងទៀត។

បណ្តាក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីការងារក្នុងឯកសារនេះ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីនេះ ដែលមានគោលដៅជំរុញបន្ថែមនូវប្រសិទ្ធភាព គុណភាពអភិបាលកិច្ច និងសន្ទុះកំណើននៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

ស្របគ្នាជាមួយនិងការបង្កើតក្រសួងរ៉ែ និងថាមពល បំបែកចេញពីអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងការដាក់ចេញនូវកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងអាណត្តិនេះ ក្រសួងរ៉ែ និងថាមពល មានកាតព្វកិច្ចត្រូវជំរុញឲ្យមានវឌ្ឍនភាពផ្លាស់ប្តូរយ៉ាងធំមួយក្នុងវិស័យធនធានរ៉ែ និងប្រេងកាតនេះ។ ក្នុងន័យនេះ ក្រសួងត្រូវការជាចាំបាច់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រច្បាស់លាស់មួយ និងភាពហ្មឺងម៉ាត់ក្នុងការអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ។ ទន្ទឹមនេះ ការអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីការងារក្នុងឯកសារនេះ ក៏នឹងអាចជំរុញក្រសួងរ៉ែ និងថាមពល ឲ្យបំពេញបាននូវតួនាទីស្នូលក្នុងការដឹកនាំ និងគ្រប់គ្រងគម្រោងអភិវឌ្ឍនានាក្នុងវិស័យធនធានរ៉ែ និងប្រេងកាត និងជំរុញសង្គតិភាពរវាងកម្មវិធី និងអន្តរាគមន៍យុទ្ធសាស្ត្រនានា របស់ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់កម្ពុជា។

## ២. ស្ថានភាពបច្ចុប្បន្ននៃវិស័យធនធានរ៉ែ និងប្រេងកាត

ថ្វីត្បិតតែឯកសារភូគព្ភសាស្ត្រដែលបន្សល់ទុកកន្លងមកថា កម្ពុជាសំបូរទៅដោយសក្តានុពលធនធានរ៉ែ និងប្រេងកាត ក៏វិស័យនេះពុំទាន់បានបង្កើតផលចំណូលជូនរដ្ឋឲ្យបានច្រើនតាមការរំពឹងទុក សម្រាប់យកមកអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជាបាននៅឡើយ ព្រោះឯកសារទាំងនោះ គ្រាន់តែបង្ហាញពីចំនុចសន្ទស្សន៍រ៉ែដែលត្រូវបានរកឃើញ ប៉ុន្តែពុំបានបង្ហាញលក្ខណៈសេដ្ឋកិច្ចនៃជម្រករ៉ែទាំងនោះទេ ។

កង្វះឯកសារ ទិន្នន័យ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការបន្សល់ទុកពីសង្គ្រាម រួមផ្សំនឹងរបបពន្ធអាករមិនទាន់ច្បាស់លាស់ ជាកត្តាចម្បងដែលមិនអាចទាក់ទាញក្រុមហ៊ុនបរទេសធំៗ ដែលមានលក្ខណៈសម្បត្តិ ហិរញ្ញវត្ថុ និងបច្ចេកទេសពិតប្រាកដខាងវិស័យនេះ មកវិនិយោគនៅកម្ពុជា។ ប៉ុន្តែឯកសារទាំងនោះអាចធ្វើឲ្យក្រុមហ៊ុនក្នុង និងក្រៅប្រទេស ដែលភាគច្រើនជាក្រុមហ៊ុនតូចៗ និងថ្មីៗ ហើយខ្លះមានបទពិសោធន៍វិនិយោគលើវិស័យសេដ្ឋកិច្ចផ្សេងៗ មានចំណាប់អារម្មណ៍ហ៊ានប្រថុយប្រថានចូលមកវិនិយោគក្នុងវិស័យនេះ ទោះបីពួកគេបានដឹងជាមុនថា ត្រូវចំណាយដើមទុនច្រើន និងប្រឈមទៅនឹងហានិភ័យខ្ពស់ក៏ដោយ ព្រោះពួកគេសង្ឃឹមថា គេអាចទទួលបានផលប្រយោជន៍ច្រើន ប្រសិនបើគេរកឃើញជម្រករ៉ែ ដែលមានសក្តានុពល ដើម្បីទៅទាក់ទាញក្រុមហ៊ុនធំៗមកចូលរួមអភិវឌ្ឍន៍ជាមួយ។

ដោយសារក្រុមហ៊ុនភាគច្រើនមានបទពិសោធន៍ខ្វីខាងវិស័យនេះ ទើបពួកគេបានចំណាយពេលសិក្សាស្រាវជ្រាវអស់ជាច្រើនឆ្នាំមកហើយ នៅតែពុំទាន់អាចវាយតម្លៃសក្តានុពលរ៉ែបានទៀត ប៉ុន្តែនៅតែមានបំណងសុំបន្តធ្វើការសិក្សាស្រាវជ្រាវបន្ត។ ចំណែកក្រុមហ៊ុនខ្លះទៀតបានយកលទ្ធផលសិក្សាស្រាវជ្រាវរ៉ែ ជាពិសេសរ៉ែមាស ដែលបានធ្វើការសិក្សា និងទទួលបានលទ្ធផល

វិជ្ជមាន ទៅធ្វើធុរកិច្ច និងស្វែងរកដៃគូអភិវឌ្ឍ ឬ អ្នកធ្វើបន្ត រួចសុំផ្ទេរសិទ្ធនៃអាជ្ញាបណ្ណស្វែងរុករកទៅឲ្យភាគីទី៣នោះ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង និងអាជីវកម្មធនធានរ៉ែ ដែលបានអនុញ្ញាតឲ្យពួកគេមានសិទ្ធសុំផ្ទេរសិទ្ធបែបនេះ។

តំបន់សម្បទានណាដែលលទ្ធផលសិក្សាស្រាវជ្រាវបង្ហាញថា បានរកឃើញរ៉ែមាស បានបង្កឲ្យមានប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្រៅតំបន់នោះ នាំគ្នាចូលទៅធ្វើសកម្មភាពជីករ៉ែមាសយ៉ាងអនាធិបតេយ្យ ដោយមានអ្នកការពារពីក្រោយថែមទៀត ហើយបានបង្កផលប៉ះពាល់ដល់បរិស្ថាន សង្គម និងបានធ្វើឲ្យបាត់បង់ចំណូលរដ្ឋ។

សម្បទានដីសេដ្ឋកិច្ចមួយចំនួន ត្រូវបានផ្តល់ជាន់លើផ្ទៃដីនៃតំបន់សម្បទាន រ៉ែ ជាហេតុបង្កឲ្យមានរំខានដល់ដំណើរការសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុនរ៉ែ ទោះបីរាជរដ្ឋាភិបាលបានកំណត់គោលការណ៍ថា ត្រូវផ្តល់សិទ្ធិឲ្យធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃសក្តានុពលរ៉ែជាមុនសិនក៏ដោយ។

ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលទាក់ទងនឹងការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែ នៅមិនទាន់គ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យការគ្រប់គ្រងវិស័យនេះនៅមានការខ្វះចន្លោះ ដើម្បីអាចជានាបញ្ញត្តិគ្រប់គ្រងលើសកម្មភាពអាជីវកម្ម ការពារបានត្រឹមត្រូវនូវផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ និងលើកកម្ពស់ភាពទទួលខុសត្រូវសេដ្ឋកិច្ចសង្គមក្នុងវិស័យនេះ។

កង្វះខាតសមត្ថភាពស្ថាប័នកិច្ច ការយល់ដឹងជាសាធារណៈចំពោះវិស័យរ៉ែ និងកង្វះធនធានមនុស្ស ក៏ជាបញ្ហាប្រឈមសំខាន់មួយដែរចំពោះវិស័យនេះ។ ជាពិសេសមន្ត្រីទទួលបន្ទុករ៉ែ សម្រាប់ពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានរ៉ែនៅកម្ពុជានៅមានចំនួនតិចតួចណាស់។ ឱកាសការងារចំពោះនិស្សិតកម្ពុជាលើវិស័យនេះ មិនទាន់មានលក្ខណៈទូលំទូលាយ។

ម្យ៉ាងទៀត ក្រុមហ៊ុនឯកជនមួយចំនួនមិនបានយកចិត្តទុកដាក់ផ្តល់ឱកាសដល់និស្សិត ដើម្បីកសាងសមត្ថភាព តាមរយៈការចុះកម្មសិក្សា ឬ ទស្សនកិច្ចផ្សេងៗ ឬ ផ្តល់អាហារូបករណ៍ជាដើម។

## ៣. ចក្ខុវិស័យ និងរបៀបវារៈយុទ្ធសាស្ត្រសំខាន់ៗ

"**ធនធានដើម្បីទាំងអស់គ្នា**" គឺជាចក្ខុវិស័យរបស់ក្រសួងរ៉ែ និងថាមពល សម្រាប់វិស័យធនធានរ៉ែ និងប្រេងកាត (ផ្នែកអាប់ស្ទ្រីម) ក្នុងការជំរុញប្រែក្លាយការវិនិយោគរបស់ជាតិលើការប្រើប្រាស់ធនធានរ៉ែ និងប្រេងកាតឲ្យប្រកបដោយទិន្នផល និងការទទួលខុសត្រូវសេដ្ឋកិច្ច-សង្គម និងបរិស្ថានខ្ពស់។

ក្រសួងរ៉ែ និងថាមពល មានបេសកកម្មបន្ថែមយ៉ាងធំធេងក្នុងការជំរុញទាញយកឲ្យអស់លទ្ធភាពនូវសក្តានុពល របស់វិស័យឧស្សាហកម្មនិស្សារណ-កម្ម ដូចជាការធ្វើអាជីវកម្ម ផលិតកម្មរ៉ែ ប្រេង និងឧស្ម័ន ដើម្បីបង្កើតនូវផលប្រយោជន៍ជាវឌ្ឍនភាពរុងរឿងរយៈពេលវែងនៃសង្គមជាតិ និងភាពល្អប្រសើរនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងអស់។

វិស័យធនធានរ៉ែ និងប្រេងកាត នឹងត្រូវជំរុញអភិវឌ្ឍន៍ឲ្យក្លាយទៅជាសសរស្តម្ភដ៏រឹងមាំ និងជាកំលាំងចលករថ្មីមួយយ៉ាងសំខាន់ សម្រាប់ការជំរុញវឌ្ឍនភាពសង្គម ការអភិវឌ្ឍន៍ធនធានមនុស្ស ការកសាងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា និងការជំរុញអភិវឌ្ឍពិពិធកម្មសេដ្ឋកិច្ច និងឧស្សាហកម្ម របស់កម្ពុជា។

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យខាងលើនេះ គោលដៅជាយុទ្ធសាស្ត្រសំខាន់ៗរបស់ក្រសួងរ៉ែ និងថាមពល សម្រាប់ឆ្នាំ ២០១៤-២០១៨ នេះ មានដូចតទៅ៖

- កសាងសមត្ថភាពស្ថាប័នកិច្ចសមស្រប និងរឹងមាំមួយសម្រាប់ជំរុញ និងគ្រប់គ្រងការអភិវឌ្ឍន៍វិស័យធនធានរ៉ែ និងប្រេងកាត
- ជំរុញកំណើនលំហូចំណូលជាតិពីវិស័យរ៉ែនាពេលបច្ចុប្បន្ន ឲ្យកើនឡើងទ្វេដង
- បង្កើតសមាហរណកម្មសេដ្ឋកិច្ច និងជំរុញកសាងអភិវឌ្ឍន៍ផ្នែកសេវាកម្ម បច្ចេកវិទ្យា និងឧបករណ៍បរិក្ខាសម្រាប់ការផ្គត់ផ្គង់បម្រើដល់វិស័យធនធានរ៉ែ និងប្រេងកាត
- ជំរុញការចាត់វិធានការ និងបញ្ញត្តិកម្ម ក្នុងការការពារ និងលើកកម្ពស់ផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន សង្គម និងបរិស្ថានធម្មជាតិ។

## ៤. វិធានការ និងកម្មវិធីការងារ

គោលដៅជាយុទ្ធសាស្ត្រខាងលើ នឹងត្រូវជំរុញឲ្យសម្រេចបានក្នុងអាណត្តិនេះ តាមរយៈការអនុវត្តន៍នូវកម្មវិធីការងារសំខាន់ៗចំនួនប្រាំ (០៥) ដូចខាងក្រោម៖

### *<u>កម្មវិធី១</u>៖ ការកសាងលិខិតបទដ្ឋានគតិយុត្ត*

ការកសាងលិខិតបទដ្ឋានគតិយុត្ត ត្រឹមត្រូវមួយសម្រាប់គ្រប់គ្រង

សកម្មភាពអាជីវកម្មធនធានរ៉ែ និងប្រេងកាត នឹងត្រូវរៀបចំជាបីកម្រិត៖ ច្បាប់ អនុក្រឹត្យ និងបទបញ្ញាបច្ចេកទេស។ ក្នុងកម្រិតច្បាប់ ក្រសួងត្រូវជំរុញរៀបចំជាបន្ទាន់នូវច្បាប់ប្រេងកាត និងច្បាប់សារពើពន្ធរ៉ែ និងប្រេងកាត។ ក្នុងកម្រិតអនុក្រឹត្យ ក្រសួងត្រូវជំរុញរៀបចំអនុក្រឹត្យប្រេងកាត (ផ្នែកអាប់ស្ទ្រីម និងដោនស្ទ្រីម) អនុក្រឹត្យពាក់ព័ន្ធនឹងអាជ្ញាបណ្ណធនធានរ៉ែ អនុក្រឹត្យស្តីពីមន្ត្រីសមត្ថកិច្ចរ៉ែ និងអនុក្រឹត្យស្តីពីសុវត្ថិភាពសុខភាពការងារក្នុងអាជីវកម្មធនធានរ៉ែ។ ក្នុងកម្រិតបទបញ្ញាបច្ចេកទេស (ប្រកាសក្រសួង) ក្រសួងត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ដូចជា៖

- លិខិតបទដ្ឋាន និងវិធានការប្រមូលចំណូលធនធានរ៉ែ និងប្រេងកាត
- លិខិតបទដ្ឋាន និងសារាចរអំពីរបាយការណ៍ប្រតិបត្តិការធនធានរ៉ែ និងប្រេងកាត និងវាយតម្លៃសេដ្ឋកិច្ចជម្រករ៉ែ និងប្រេងកាត
- សារាចរអំពីការរៀបចំកម្មវិធីការងារសិក្សាស្វែងរុករករ៉ែ និងប្រេងកាត
- សារាចរអំពីការរៀបចំផែនការបិទការដ្ឋានអាជីវកម្មធនធានរ៉ែ និងប្រេងកាត និងការស្តារបរិស្ថានឡើងវិញ
- សារាចរស្តីពីស្តង់ដារសុវត្ថិភាពបរិស្ថាន និងសង្គម និងការវាយតម្លៃយុទ្ធសាស្ត្រនៃផែនការបរិស្ថាន ក្នុងគម្រោងអាជីវកម្មរ៉ែ និងប្រេងកាត
- ប្រកាសប្រតិភូកម្មមុខងារថ្នាក់ក្រោមជាតិ សម្រាប់វិស័យធនធានរ៉ែ និងប្រេងកាត

- ប្រកាសកំណត់និតិវិធី និងបទបញ្ញាបច្ចេកទេសពាក់ព័ន្ធសិប្បកម្មធនធានរ៉ែ និងអាជីវកម្មរ៉ែសំណង់
- គំរូកិច្ចព្រមព្រៀងរ៉ែ និងប្រេងកាត។ល។

## *<u>កម្មវិធី២</u>៖ ការកសាងសមត្ថភាព និងពង្រឹងស្ថាប័នកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

ការកសាងសមត្ថភាព និងពង្រឹងស្ថាប័នកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏ចាំបាច់ ដើម្បីជំរុញឲ្យការអនុវត្តកម្មវិធីយុទ្ធសាស្ត្រទាំងបីខាងលើមានប្រសិទ្ធភាព មានភាពសាកសិទ្ធ និងប្រកបដោយទិន្នផល។ ការកសាងសមត្ថភាព និងពង្រឹងស្ថាប័នកិច្ចត្រូវសង្កត់ធ្ងន់លើជំនាញ និងចំណេះដឹងអាទិភាពដូចតទៅ៖

- ការគ្រប់គ្រង និងការប្រមូលចំណូលជាតិពីវិស័យធនធានរ៉ែ និងប្រេងកាត
- ការគ្រប់គ្រង និងដំណើរការការចុះបញ្ជីធនធានរ៉ែ និងប្រេងកាត
- សេដ្ឋកិច្ចធនធានរ៉ែ និងប្រេងកាត
- ភូគព្ភសាស្ត្របរិស្ថាន ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសុវត្ថិភាព នៃអាជីវកម្មរ៉ែ និងប្រេងកាត
- ស្តង់ដារសុវត្ថិភាពបរិស្ថាន និងសង្គម និងការវាយតម្លៃយុទ្ធ-សាស្ត្រនៃផែនការបរិស្ថាន ក្នុងគម្រោងអាជីវកម្មរ៉ែ និងប្រេងកាត
- ការសិក្សាចងក្រងទិន្នន័យ និងផែនទីភូគព្ភសាស្ត្រ និងជម្រករ៉ែ និងប្រេងកាត

- អធិការកិច្ចសុវត្ថិភាពការងារ និងសុខភាពនៅការដ្ឋានអាជីវកម្មរ៉ែ
- ច្បាប់អន្តរជាតិ គម្រូកិច្ចអភិវឌ្ឍតំបន់ត្រួតគ្នា និងការសហការរួមបញ្ចូលអាជីវកម្មធនធានរ៉ែ
- មន្ទីរពិសោធន៍ និងសារៈមន្ទីរភូគព្ភសាស្ត្ររ៉ែ និងប្រេងកាត។

ការកសាងសមត្ថភាពជាតិខាងវិស័យធនធានរ៉ែ និងប្រេងកាត ត្រូវរួមបញ្ចូលទាំងការកសាងនូវបណ្ដាញសម្ព័ន្ធភាពការងារ និងកិច្ចសហការរវាងអង្គការសង្គម ស្ថាប័នអប់រំនិងស្រាវជ្រាវ និងសមាគមន៍ឧស្សាហកម្មធនធានរ៉ែរបស់ផ្នែកឯកជន ក្នុងគោលដៅជួយបំពេញឲ្យគ្នាទៅវិញទៅមក និងជានាសង្គតិភាពក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញប្រែក្លាយវិស័យធនធានរ៉ែ និងប្រេងកាតឲ្យប្រកបដោយការទទួលខុសត្រូវសេដ្ឋកិច្ច សង្គម និងបរិស្ថានខ្ពស់។

## *<u>កម្មវិធី៣</u>៖ ការជំរុញកំណើនលំហូរចំណូលជាតិពីវិស័យធនធានរ៉ែ និងប្រេងកាត*

កម្មវិធីការងារនេះ មានវិធានការសំខាន់ៗដែលត្រូវអនុវត្តចំនួនបួន (០៤) គឺ៖

1. ការជំរុញរកឃើញនូវជម្រកធនធានរ៉ែ និងសក្ដានុពលធនធានប្រេង និងឧស្ម័នថ្មីៗបន្ថែមទៀត។
2. ការជំរុញកៀរគរវិនិយោគទុនបរទេសក្នុងវិស័យធនធានរ៉ែ និងប្រេងកាត

3. ការជំរុញឲ្យមានការចាប់ផ្តើមដំណើរការអាជីវកម្ម ផលិតកម្ម ធនធានប្រេង ឧស្ម័ន និងរ៉ែរបស់កម្ពុជា។
4. ការជំរុញលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រមូល និងគ្រប់គ្រងចំណូលជាតិពីវិស័យធនធានរ៉ែ និងប្រេងកាត។

## *កម្មវិធី៤៖ ការជំរុញសមាហរណកម្មសេដ្ឋកិច្ច*

កម្មវិធីការងារនេះ មានវិធានការសំខាន់ៗដែលត្រូវអនុវត្តចំនួនបី (០៣) គឺ៖

1. ការជំរុញការប្រើប្រាស់ជាអតិបរិមានូវផលិតផល និងសេវាកម្មក្នុងស្រុក។
2. ការជំរុញការបង្កើតឧស្សាហកម្មគាំទ្រ ផ្នែកសេវាកម្ម បច្ចេកវិទ្យា និងឧបករណ៍បរិក្ខារ។
3. ការគ្រប់គ្រងការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងនាំចេញផលិតផលរ៉ែ ប្រេង និងឧស្ម័ន ផ្អែកលើអភិក្រមទីផ្សារ។

## *កម្មវិធី៥៖ ការជំរុញភាពទទួលខុសត្រូវសង្គម និងបរិស្ថាន*

កម្មវិធីការងារនេះ មានវិធានការសំខាន់ៗដែលត្រូវអនុវត្តចំនួនប្រាំ (០៥) គឺ៖

1. ការជំរុញការសម្របសម្រួល និងភាពបំពេញគ្នាទៅវិញទៅមករវាងគម្រោងរ៉ែ និងប្រេងកាត ជាមួយគម្រោងអភិវឌ្ឍមូលដ្ឋាន និងផែនការប្រើប្រាស់ដីធ្លី

2. ការជំរុញលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍មូលដ្ឋាន ជាពិសេសស្ត្រីក្នុងគ្រប់ដំណាក់កាលអភិវឌ្ឍរបស់វិស័យធនធានរ៉ែ និងប្រេងកាត
3. ការជំរុញការអនុវត្តកម្មវិធីសង្គមរបស់ក្រុមហ៊ុនរ៉ែ និងប្រេងកាតសម្រាប់សហគមន៍ មូលដ្ឋាន និងការជំរុញឲ្យមានការអនុវត្តគម្រោងការ ឬ កម្មវិធីលើកកម្ពស់ជីវភាពរបស់ សហគមន៍មូលដ្ឋាន
4. ការជំរុញការលើកកម្ពស់ប្រសិទ្ធិភាពនៃការអនុវត្តប្រព័ន្ធការពារសុវត្ថិភាពបរិស្ថាន និងសង្គម និងការវាយតម្លៃយុទ្ធសាស្ត្រនៃផែនការបរិស្ថាន ក្នុងគម្រោងអាជីវកម្មរ៉ែ និងប្រេងកាត
5. ការជំរុញការគ្រប់គ្រង និងចូលក្នុងប្រព័ន្ធ (Formalization) នូវសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ និងខ្នាតតូច។

## ៥. អាទិភាពកម្មវិធីការងារ និងពេលវេលាអនុវត្ត

បណ្តាកម្មវិធីការងារជាយុទ្ធសាស្ត្រខាងលើ នឹងត្រូវកំណត់ជាអាទិភាពសម្រាប់អនុវត្តក្នុងដំណាក់កាលដូចតទៅ៖

### ក. ឆ្នាំ ២០១៤-២០១៦

ក្នុងរយៈពេលពាក់កណ្តាលអាណត្តិដំបូងនេះ ស្របពេលគ្នានឹងក្រសួងរ៉ែ និងថាមពល ទើបនឹងបានបង្កើតឡើង ដូច្នេះ អាទិភាពចំបងរបស់ក្រសួង គឺសង្កត់ធ្ងន់លើកម្មវិធីទី១៖ ការកសាងលិខិតបទដ្ឋានគតិយុត្ត និង

កម្មវិធីទី២៖ ការកសាងសមត្ថភាព និងពង្រឹងស្ថាប័នកិច្ច ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់វិស័យនេះ។ បន្ថែមលើកម្មវិធីការងារអាទិភាពទាំងពីរនេះ ក្រសួងក៏នឹងចាត់វិធានការចាំបាច់មួយចំនួនទៀតដូចខាងក្រោម ដើម្បីជំរុញកំណែទម្រង់ លើកកម្ពស់ប្រសិទ្ធិភាព និងតម្លាភាពក្នុងវិស័យធនធានរ៉ែ និងប្រេងកាត៖

- រឹតបន្តឹងការត្រួតពិនិត្យ និងប្រសិទ្ធភាពនៃការអនុវត្តន៍កាតព្វកិច្ចកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ កិច្ចព្រមព្រៀងប្រេងកាត និងត្រួតពិនិត្យឡើងវិញនូវរាល់អាជ្ញាបណ្ណធនធានរ៉ែទាំងអស់ ដែលកំពុងមានសុពលភាព
- រៀបចំយន្តការផ្តល់អាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែថ្មី ដែលមានតម្លាភាព តាមរយៈការត្រួតពិនិត្យហ្មឹងម៉ាត់លើសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងការចុះបញ្ជីពាណិជ្ជកម្ម និងការវាយតម្លៃបឋមលើផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម និងការរៀបចំផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានអាជ្ញាបណ្ណធនធានរ៉ែ
- រៀបចំ និងអនុវត្តគម្រោងសាកល្បងការដេញថ្លៃសម្បទានធនធានរ៉ែ ចំពោះតំបន់ដែលសក្តានុពលធនធានរ៉ែត្រូវបានយល់ដឹងរួចហើយ
- រៀបចំយន្តការ និងក្របខ័ណ្ឌអនុវត្ត ដើម្បីពង្រឹងស្តង់ដារសុវត្ថិភាពបរិស្ថាន និងសង្គម និងការវាយតម្លៃយុទ្ធសាស្ត្រនៃផែនការបរិស្ថានក្នុងគម្រោងអាជីវកម្មរ៉ែ និងប្រេងកាត។

## ខ. ឆ្នាំ ២០១៦-២០១៨

ក្នុងដំណាក់កាលនេះ ក្រសួងផ្ដោតអាទិភាពសំខាន់លើកម្មវិធីទី៣៖ ជំរុញកំណើនលំហូចំណូលជាតិពីវិស័យរ៉ែ កម្មវិធីទី៤៖ ជំរុញសមាហរណកម្មសេដ្ឋកិច្ចនៃវិស័យធនធានរ៉ែ និងកម្មវិធីទី៥៖ ជំរុញភាពទទួលខុសត្រូវសង្គម និងបរិស្ថាន។ វិធានការដ៏សំខាន់ជាបន្ថែម ក្នុងការអនុវត្តន៍កម្មវិធីទាំងនេះ គឺការកសាងជាពិសេសសមត្ថភាពថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន ក្នុងការចូលរួម និងទាក់ទាញយកផលប្រយោជន៍សេដ្ឋកិច្ចពីការអភិវឌ្ឍន៍វិស័យធនធានរ៉ែ និងប្រេងកាត នៅក្នុងមូលដ្ឋានរបស់ខ្លួននីមួយៗ។

# ៦. សន្ទស្សន៍ប្រសិទ្ធផលរំពឹងទុក សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍ ក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ

លទ្ធផលនៃការអនុវត្តន៍ នឹងត្រូវត្រួតពិនិត្យវាយតម្លៃ នៅចុងបញ្ចប់នៃពាក់កណ្ដាលអាណត្តិ (២០១៦) និងនៅចុងបញ្ចប់នៃអាណត្តិ (២០១៨) ដូចខាងក្រោម៖

## *ក. នៅចុងពាក់កណ្ដាលអាណត្តិ (ឆ្នាំ ២០១៦)*

សន្ទស្សន៍ប្រសិទ្ធផលសំខាន់ៗ នៃការអនុវត្តកម្មវិធីការងារ និងវិធានការបន្ថែមក្នុងដំណាក់កាលនេះ មានដូចតទៅ៖

### *ក.១.សន្ទស្សន៍ប្រសិទ្ធផលពាក់ព័ន្ធនឹងសមត្ថភាពស្ថាប័នកិច្ចក្នុងវិស័យធនធានរ៉ែ និងប្រេងកាត*

1. សេចក្ដីព្រាងច្បាប់ប្រេងកាត ត្រូវបានអនុម័តដោយទីស្ដីការគណៈរដ្ឋមន្ត្រី

2. អនុក្រឹត្យស្តីពីអាជ្ញាបណ្ណស្វែងរុករក និងឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវបានអនុម័ត

3. អនុក្រឹត្យប្រេងកាត (ផ្នែកអាប់ស្ទ្រីម និងដោនស្ទ្រីម) ត្រូវបានអនុម័ត

4. អនុក្រឹត្យស្តីពីមន្ត្រីសមត្ថកិច្ចរ៉ែ ត្រូវបានអនុម័ត

5. នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធវិស័យរ៉ែទាំងថ្នាក់ជាតិ និងក្រោមជាតិ មានការរៀបចំរចនា សម្ព័ន្ធ ការបែងចែកមុខងារ តួនាទី ភារកិច្ច និងអាចម្ចាស់ការគ្រប់គ្រាន់ក្នុងការគ្រប់គ្រងតាមដាន ត្រួតពិនិត្យវាយតម្លៃ និងអនុវត្តន៍ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យធនធានរ៉ែ និងប្រេងកាត

6. បណ្តាញសង្គមរវាងក្រសួង សមាគមន៍ឧស្សាហកម្មវិស័យធនធានរ៉ែ និងប្រេងកាត អង្គការសង្គម និងគ្រឹះស្ថានសិក្សាអប់រំផ្សេងៗ ពាក់ព័ន្ធនឹងវិស័យធនធានរ៉ែ និងប្រេងកាត ត្រូវបានបង្កើតឡើង និងដំណើរការ។

## ***ក.២. សន្ទស្សន៍ប្រសិទ្ធផលពាក់ព័ន្ធនឹងអភិបាលកិច្ចវិស័យរ៉ែ***

7. ប្រព័ន្ធវាយតម្លៃការចេញអាជ្ញាបណ្ណធនធានរ៉ែថ្មី ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព

8. យ៉ាងហោចណាស់ការចេញអាជ្ញាបណ្ណធនធានរ៉ែ ឬ កិច្ចព្រមព្រៀងវិនិយោគទុនរ៉ែចំនួនមួយ ត្រូវបានអនុវត្តដោយការដេញថ្លៃជាសាធារណៈ

9. ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីធនធានរ៉ែ និងប្រេងកាត ត្រូវបានបង្កើតឡើង និងដំណើរការសម្រាប់ពិនិត្យដោយសាធារណៈ

10. រាល់គម្រោងអាជីវកម្មធនធានរ៉ែត្រូវបានអនុវត្តស្របតាមទម្រង់ និងគំនូសប្លង់បច្ចេកទេស និងផែនការផលិតកម្មច្បាស់លាស់ ក្រោមការត្រួតពិនិត្យដោយមន្ត្រីសមត្ថកិច្ចរបស់ក្រសួង

11. ចំនួន និងទំហំសកម្មភាពជីករ៉ែអនាធិបតេយ្យ ត្រូវបានកាត់បន្ថយជាអតិបរិមា ហើយយន្តការគ្រប់គ្រង ត្រូវបានបង្កើតឡើង និងដំណើរការដោយប្រសិទ្ធិភាព។

## *ក.៣. សន្ទស្សន៍ប្រសិទ្ធផលពាក់ព័ន្ធនឹងលំហូចំណូលជាតិពីវិស័យរ៉ែ និងប្រេងកាត*

12. ភាពអសកម្មក្នុងប្រតិបត្តិការធនធានរ៉ែ ត្រូវបានកាត់បន្ថយ ហើយប្រសិទ្ធផលនៃការអនុវត្តន៍កាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងវិនិយោគទុនរ៉ែ ត្រូវបានកើនឡើង

13. ប្រព័ន្ធគ្រប់គ្រងថវិកា និងបញ្ជីការគណនេយ្យចំណូលធនធានរ៉ែ និងប្រេងកាត ត្រូវបានបង្កើតឡើង និងដំណើរការ

14. គំរូសេដ្ឋកិច្ចធនធានរ៉ែ និងប្រេងកាត ត្រូវបានបង្កើតឡើង និងដំណើរការបម្រើដល់ការវិភាគសេដ្ឋកិច្ចសារពើពន្ធក្នុងកិច្ចសន្យាប្រេងកាត និងការវាយតម្លៃការសិក្សាសមិទ្ធិលទ្ធភាពជម្រករ៉ែ

15. ប្រព័ន្ធគ្រប់គ្រងទិន្នន័យភូគព្ភសាស្ត្រជម្រករ៉ែ និងកសាងផែនទី ត្រូវបានបង្កើតឡើង និងដំណើរការ បម្រើដល់ការកៀរគរ និងទាក់ទាញវិនិយោគទុនធនធានរ៉ែ និងប្រេងកាត

16. ព័ត៌មានចំណាត់ថ្នាក់ជម្រករ៉ែ និងប្រេងកាត និងសក្តានុពលសេដ្ឋកិច្ចធនធានរ៉ែ និងប្រេងកាតកម្ពុជា ត្រូវបានបង្កើតឡើង និងបម្រើដល់ការរៀបចំផែនការសេដ្ឋកិច្ចធនធានរ៉ែ និងប្រេងកាត និងការគ្រប់គ្រងការប្រមូលចំណូលធនធានរ៉ែ និងប្រេងកាត។

## *ខ. នៅចុងអាណត្តិ (ឆ្នាំ ២០១៨)*

សន្ទស្សន៍ប្រសិទ្ធផលសំខាន់ៗ នៃការអនុវត្តកម្មវិធីការងារ និងវិធានការបន្ថែមក្នុងដំណាក់កាលនេះ មានដូចតទៅ៖

1. សមាសភាពសេដ្ឋកិច្ចនៃផ្នែកឧស្សាហកម្មផ្គត់ផ្គង់ ឧបករណ៍បរិក្ខារ បច្ចេកវិទ្យា និងសេវាកម្ម បម្រើដល់វិស័យធនធានរ៉ែ និងប្រេងកាត ត្រូវបានកំណត់ច្បាស់លាស់ និងអាចវាយតម្លៃបាន។
2. យ៉ាងតិចមានគម្រោងអាជីវកម្មធនធានរ៉ែកម្រិតស្តង់ដារអន្តរជាតិមួយ ត្រូវបានដំណើរការ និងបង្កើតផលសេដ្ឋកិច្ចសង្គមយ៉ាងសំខាន់ដល់កម្ពុជា។
3. យ៉ាងហោចណាស់ មាន Platform ផលិតកម្មប្រេង និងឧស្ម័នមួយ ត្រូវបានសាងសង់រួច និងអាចចាប់ផ្តើមដំណើរការផលិតប្រេងកាតរបស់កម្ពុជាជាលើកទីមួយ។
4. ក្រុមហ៊ុនជាតិវិស័យប្រេងកាត ត្រូវបានបង្កើតឡើង និងមានដំណើរការ។
5. ផលចំណូលជាតិពីវិស័យធនធានរ៉ែ និងប្រេងកាតបានកើនឡើងទ្វេដង ប្រៀបធៀបនឹងឆ្នាំ២០១៤។

6. សមត្ថភាពជាតិសម្រាប់ការគ្រប់គ្រង ត្រួតពិនិត្យ និងតាមដាន វាយតម្លៃលើការការពារសុវត្ថិភាពសុខភាព បរិស្ថាន និងការទទួលខុសត្រូវសង្គម ត្រូវបានបង្កើតឡើង និងមានដំណើរការ។
7. សកម្មភាពអាជីវកម្មធនធានរ៉ែទាំងអស់ ត្រូវបានគ្រប់គ្រង និងមានភាពអនុលោមត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ៧. គោលការណ៍មូលដ្ឋានរបស់ក្រសួងរ៉ែ និងថាមពល ក្នុងយុទ្ធសាស្ត្រធនធានរ៉ែ ២០១៨

ក្នុងការជំរុញអនុវត្តន៍ក្របខ័ណ្ឌយុទ្ធសាស្ត្រខាងលើ និងស្របតាមទស្សនវិស័យរបស់ខ្លួន ក្រសួងរ៉ែ និងថាមពល ប្រកាន់ភ្ជាប់នូវគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- រាល់ការបង្កផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវមានការទទួលខុសត្រូវ និងទូទាត់សំណងខូចខាត ស្តារឡើងវិញ និង/ឬ ចាត់វិធានការកែលំអ ដោយបុគ្គលដែលបានបង្កផលប៉ះពាល់ទាំងនោះ
- ត្រូវជំរុញឲ្យមានការទទួលខុសត្រូវ និងតម្លាភាពចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងសហគមន៍មូលដ្ឋានដែលទទួលផលប៉ះពាល់
- សិទ្ធិស្របច្បាប់ សមធម៌ យេនឌ័រ និងយុត្តិធម៌ក្នុងការទទួលផលពីការអភិវឌ្ឍន៍ធនធានរ៉ែ ត្រូវជំរុញបង្កើតឡើង និងពង្រឹងឲ្យកាន់

តែប្រសើររវាងអ្នកវិនិយោគ និងផ្នែកផ្សេងៗនៃសង្គម (សហគមន៍មូលដ្ឋាន ជនជាតិភាគតិចៗលៗ) ព្រមទាំងសិទ្ធ និងផលប្រយោជន៍របស់មនុស្សជំនាន់ក្រោយត្រូវបានជានាការពារ

- ប្រព័ន្ធការពារ និងស្តង់ដារសុវត្ថិភាពបរិស្ថាន និងសង្គម ត្រូវជំរុញឲ្យមានភាពសមស្របតាមបទដ្ឋាន និងការអនុវត្តន៍ទូទៅជាអន្តរជាតិ សម្រាប់អាជីវកម្មធនធានរ៉ែ និងប្រេងកាត។

## ៨. កំណែទម្រង់ស្ថាប័នកិច្ចរបស់ក្រសួងរ៉ែ និងថាមពល

ក្នុងការជំរុញ និងអនុវត្តបណ្តាយុទ្ធសាស្ត្រ និងកម្មវិធីការងារខាងលើ ក្រសួងរ៉ែ និងថាមពល នឹងជំរុញការអភិវឌ្ឍន៍សមត្ថភាពប្រតិបត្តិការរបស់បណ្តានាយកដ្ឋាន និងអង្គភាពនានារបស់ខ្លួន ឲ្យមានការប្រកាន់ខ្ជាប់នូវលក្ខណៈសម្បត្តិចំនួនប្រាំ (០៥)ដូចតទៅៈ

1. មានភាពឆ្លើយតបខ្ពស់ ចំពោះតម្រូវការរបស់វិស័យសាធារណៈ និងឯកជន។
2. មានភាពជាម្ចាស់ និងជាអ្នកដឹកនាំ ក្នុងការកំណត់ និងអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអន្តរាគមន៍នានាពាក់ព័ន្ធនឹងវិស័យធនធានរ៉ែ និងប្រេងកាត។
3. មានការទទួលខុសត្រូវវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ នៅក្នុងសកម្មភាពនានា និងភាពជាដៃគូរក្នុងកម្មវិធីផ្សេងៗរបស់ខ្លួន។
4. មានការប្តេជ្ញាចិត្តខ្ពស់ក្នុងភាពជាដៃគូរក្នុងការអភិវឌ្ឍន៍ ជាមួយ

អង្គការ ស្ថាប័ន សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធនានា នៅក្នុងការរៀបចំ និងអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការវិស័យធនធានរ៉ែ និងប្រេងកាត។

5. មានវិធីសាស្ត្រការងារ ដោយផ្អែកលើប្រសិទ្ធផលជាមូលដ្ឋាន (Performance Based) នៅក្នុងការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍យុទ្ធសាស្ត្រ និងកម្មវិធីការងារផ្សេងៗរបស់ខ្លួន។